ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីការចូលជាធរមាន នៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប-RCEP) នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា អនុលោមតាមមាត្រា ២០.៦ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប-RCEP) នឹងចូលជាធរមាន នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២។

កិច្ចព្រមព្រៀងអាសិប ជាគំនិតផ្តួចផ្តើមរបស់អាស៊ាន និងត្រូវបានប្រកាសឱ្យចាប់ផ្តើមការចរចាក្នុងឆ្នាំ ២០១២ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចព្រមព្រៀងនេះគឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដ៏ធំបំផុតលើពិភពលោក ដែលមានសមាជិកចំនួន១៥ប្រទេស រួមមានប្រទេសសមាជិកអាស៊ានទាំង១០ និងប្រទេសដៃគូពាណិជ្ជកម្មសេរីអាស៊ានចំនួន៥ ដូចជា ប្រទេសអូស្ត្រាលី ចិន ជប៉ុន កូរ៉េខាងត្បូង និង ណូវែលហ្សេឡង់ និងគ្របដណ្តប់៖ (១) ប្រជាជនប្រមាណ២.២ពាន់លាននាក់ ឬ៣០% នៃចំនួនប្រជាជនពិភពលោក (២) ផលិតផលក្នុងស្រុកសរុបប្រមាណ ២៦.២ ទ្រីលានដុល្លារអាមេរិក ឬ ៣០% នៃផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក និង (៣) ទំហំពាណិជ្ជកម្មចំនួនប្រមាណ ២៨% នៃទំហំពាណិជ្ជកម្មពិភពលោកទាំងមូល។

ផ្អែកតាមលទ្ធផលនៃការសិក្សារបស់ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) បានបង្ហាញថា កម្ពុជាអាចនឹងមានកំណើនប្រចាំឆ្នាំការនាំចេញចំនួន ៧,៣% វិនិយោគចំនួន ២៣,៤% និងផលិតផលក្នុងស្រុកសរុបចំនួនប្រមាណ ២% លើផលិតផលក្នុងស្រុកសរុប ដែលមានបច្ចុប្បន្ន។

កម្ពុជា ទទួលបានភាពអនុគ្រោះពន្ធពីកិច្ចព្រមព្រៀងនេះលើទំនិញសំខាន់ៗជាច្រើន ដែលបញ្ជីទំនិញទាំងអស់អាចទាញយកបានពីគេហទំព័រក្រសួងពាណិជ្ជកម្ម។ ក្រសួងពាណិជ្ជកម្ម សូមលើកឧទាហរណ៍មុខទំនិញមួយចំនួនដូចខាងក្រោម៖

- **ទំនិញកសិកម្ម** រួមមាន៖ គ្រាប់ស្វាយចន្ទី, ពោត, ដូង, ស្វាយស្រស់, ចេក, ដំលូងជ្វា, ទឹកឃ្មុំ, ម្រេចមៀត, ក្រូច, ល្ហុង, ផ្លែផាសិន, ខ្ទឹម, ត្រប់ែក, ស្រកានាគ, ទុរេន, ...។ល។
- **ទំនិញកសិកម្មកែច្នៃ** រួមមាន៖ គុយទាវ, នំក្រៀម, សំបុកត្រចៀកកាំ, ទំនិញកែច្នៃពីត្រី, ម្សៅដំឡូងមី, ទំនិញកែច្នៃពីដូង, ប្រេងសណ្តែកដី, សាច់ក្រក, ទឹកម្ទេស, ដំណាប់ចេក, ដំណាប់ស្វាយ, ដំណាប់ទុរេន, មីកញ្ចប់, ...។ល។
- **ទំនិញឧស្សាហកម្ម** រួមមាន៖ កង់, សំលៀកបំពាក់, ស្បែកជើង, គ្រឿងបង្គុំអេឡិចត្រូនិក, ខ្សែកាបអេឡិចត្រូនិកអគ្គិសនី, គ្រឿងសង្ហារឹម, ស្ករស, ស្ករអំពៅ, កាបូបយួរដៃ, វ៉ាលី, ខ្សែភ្លើង, សម្ភារកីឡា, ជ័រកែច្នៃ, សំបកថ្នាំពេទ្យ, ជ័រកៅស៊ូធម្មជាតិរាវ, កៅស៊ូក្នុងទម្រង់បន្ទះ, កៅស៊ូឡាតិច, ក្រណាត់ក្រាល, កំទេចឈើកែច្នៃ,...។ល។



ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ ០២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469

កម្ពុជាក៏នឹងទទួលបានអត្ថប្រយោជន៍បន្ថែមពីកិច្ចព្រមព្រៀងនេះមានជាអាទិ៍ ការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង ចំណេះធ្វើ និងជំនាញថ្មីៗពីការវិនិយោគផ្ទាល់របស់បរទេស ព្រមទាំងបង្កើតការងារថ្មីៗជូនប្រជាជនកម្ពុជា ផងដែរ។ កិច្ចព្រមព្រៀងនេះក៏នឹងជួយជំរុញកំណើននៃការនាំចេញ និងកំណើនផលទុនសរុបក្នុងស្រុក ព្រមទាំងជួយស្តារឡើងវិញនូវសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានឆាប់រហ័ស ដែលទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩។

កិច្ចព្រមព្រៀងអាសិប មានគោលបំណងបង្កើតបរិយាកាសពាណិជ្ជកម្មនិងវិនិយោគបើកចំហ ដើម្បីសម្រួលដល់ការពង្រីកពាណិជ្ជកម្មនិងការវិនិយោគក្នុងតំបន់ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសកលលោក។ កិច្ចព្រមព្រៀងអាសិប នឹងក្លាយជាក្របខ័ណ្ឌស្នូលសម្រាប់ការធ្វើពាណិជ្ជកម្មនិងការវិនិយោគ ដើម្បីពង្រីកបន្ថែមទៀតនូវខ្សែច្រវាក់តម្លៃតំបន់ នាំមកនូវឱកាសទីផ្សារនិងការងារ សម្រាប់អាជីវកម្មនិងប្រជាជននៅក្នុងតំបន់។

កិច្ចព្រមព្រៀងនេះមាន មាន ២០ជំពូក ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

- **ជំពូកទី១ បទប្បញ្ញត្តិដើមនិងនិយមន័យទូទៅ៖** បានកំណត់ពីគោលបំណងនៃការចរចាអាសិប ក្នុងការបង្កើតភាពជាដៃគូសេដ្ឋកិច្ចដែលមានលក្ខណៈទំនើប គុណភាពខ្ពស់ និងផ្តល់អត្ថប្រយោជន៍ឱ្យគ្នា ទៅវិញទៅមក ដោយគិតគូរពីភាពខុសគ្នានៃការអភិវឌ្ឍនិងតម្រូវការសេដ្ឋកិច្ចរបស់ភាគីនានា ជាពិសេសសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច។
- **ជំពូកទី២ ពាណិជ្ជកម្មទំនិញ៖** បានធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញបន្ថែម និងផ្តល់ភាពអនុគ្រោះទីផ្សារ តាមរយៈការធ្វើសេរីភាវូបនីយកម្មពន្ធគយជាបន្តបន្ទាប់ ជាពិសេសការលុបបំបាត់ពន្ធគយក្នុងរយៈពេលសមស្រប ការលុបបំបាត់ការឧបត្ថម្ភធននាំចេញកសិកម្ម ការលុបបំបាត់ជាទូទៅនៃការរឹតបន្តឹងបរិមាណ និងបំពេញបន្ថែមការធ្វើសេរីភាវូបនីយកម្មពន្ធគយ គោលការណ៍ទាក់ទងនឹងការអនុវត្តវិធានការមិនមែនពន្ធ នីតិវិធីរដ្ឋបាលសម្រាប់អាជ្ញាបណ្ណនាំចូលនិងការអនុវត្តកម្រៃសេវា និងបែបបទទាក់ទងនឹងការនាំចេញនិងនាំចូល។
- **ជំពូកទី៣ វិធានដើមកំណើតទំនិញ៖** បានដាក់ចេញនូវគោលការណ៍ណែនាំ វិធានដើម្បីកំណត់ និងបញ្ជាក់ដើមកំណើតទំនិញដែលមានភាពងាយស្រួលជាងមុន ដើម្បីទទួលបានការអនុគ្រោះពន្ធ ជាពិសេសតាមរយៈវិធានបូកបន្ថែមតម្លៃតំបន់ (Regional Cumulation) ដែលអនុញ្ញាតឱ្យប្រទេសជាសមាជិក បូកបញ្ចូលតម្លៃនៃវត្ថុធាតុដើម ដែលនាំចូលពីប្រទេសសមាជិកអាសិបទាំង១៥ ក្នុងដំណើរការផលិតនិងនាំចេញទៅប្រទេសអាសិបវិញ។
- **ជំពូកទី៤ នីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម៖** បានបង្កើតបរិយាកាសអំណោយផល សំដៅធ្វើឱ្យរីកចម្រើនខ្សែច្រវាក់ផ្គត់ផ្គង់តំបន់និងសកល តាមរយៈបទប្បញ្ញត្តិដែលសាមញ្ញ អាចប៉ាន់ស្មានបាន និងមានតម្លាភាព ក្នុងការអនុវត្តច្បាប់និងបទប្បញ្ញត្តិគយ និងលើកកម្ពស់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃនីតិវិធីគយ និងបញ្ចេញទំនិញបានឆាប់រហ័ស ស្របតាមការអនុវត្តនិងស្តង់ដារល្អបំផុតអន្តរជាតិ។
- **ជំពូកទី៥ អនាម័យ និងភូតគាមអនាម័យ៖** បានដាក់ចេញនូវក្របខណ្ឌមូលដ្ឋានសម្រាប់ការរៀបចំ អនុម័ត និងអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យ ក្នុងគោលបំណងធានាសុវត្ថិភាពចំណីអាហារ និងការពារជីវិតមនុស្ស សត្វ រុក្ខជាតិ ឬសុខភាព ដោយធានាថាវិធានការអនាម័យ និងភូតគាមអនាម័យ ត្រូវអនុវត្ត តែក្នុងស្ថានភាពចាំបាច់បំផុតដើម្បីការពារសុខភាព និងកាត់បន្ថយផលប៉ះពាល់មកលើពាណិជ្ជកម្ម។
- **ជំពូកទី៦ ស្តង់ដារ បទដ្ឋានបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព** បានពង្រឹងការអនុវត្តកិច្ចព្រមព្រៀងរបាំងបច្ចេកទេសពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងលើកកម្ពស់ការយល់ដឹងពីគ្នាទៅវិញទៅមកអំពីស្តង់ដារ បទដ្ឋានបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាពរបស់ភាគីនីមួយៗ ក៏ដូចជាពង្រឹងនិងសហការក្នុងការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ដើម្បីកាត់បន្ថយរបាំងបច្ចេកទេសដែលមិនចាំបាច់សម្រាប់ការធ្វើពាណិជ្ជកម្ម។

- **ជំពូកទី៧ ឧបាស្រ័យពាណិជ្ជកម្ម** បានដាក់ចេញនូវវិធានការការពារ និងការប្រឆាំងការលក់បង្ខូចថ្លៃ និងវិធានការពន្ធប៉ះប៉ូវ ដែលអនុញ្ញាតឱ្យភាគីនីមួយៗប្រើប្រាស់យន្តការដើម្បីដោះស្រាយការខាតបង់ ឬការគំរាមកំហែងការខាតបង់ដល់ឧស្សាហកម្មក្នុងស្រុក ដោយផ្អែកលើសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងពាក់ព័ន្ធនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។

- **ជំពូកទី៨ ពាណិជ្ជកម្មសេវាកម្ម** បានធ្វើសេរីភាវូបនីយកម្មកាន់តែទូលាយ ដែលនឹងបើកផ្លូវឱ្យការធ្វើពាណិជ្ជកម្មសេវាកម្មកាន់តែប្រសើរឡើង តាមរយៈការកាត់បន្ថយភាពរឹតត្បិត និងវិធានការណ៍រើសអើងសម្រាប់ ពាណិជ្ជកម្ម ឆ្លងកាត់ព្រំដែនក្នុងវិស័យសេវាកម្ម។

- **ជំពូកទី៩ បម្លាស់ទីរូបវន្តបុគ្គល** បានដាក់ចេញនូវកាតព្វកិច្ចរបស់ភាគីនៃកិច្ចព្រមព្រៀងអាសិប ទាក់ទងនឹងការសម្របសម្រួលនៃការចូល និងការស្នាក់នៅបណ្តោះអាសន្ននៃរូបវន្តបុគ្គល ដែលចូលរួមក្នុងពាណិជ្ជកម្មទំនិញ ការផ្គត់ផ្គង់សេវាកម្ម ឬការវិនិយោគ អាស្រ័យលើលក្ខខណ្ឌ និងការកំណត់នៅក្នុងតារាងសន្យា ដូចជារយៈពេលនៃការស្នាក់នៅជាដើម។

- **ជំពូកទី១០ ការវិនិយោគ** បានបង្កើតបរិយាកាសវិនិយោគដែលមានភាពសេរីនៅក្នុងតំបន់ និងបានដាក់ចេញនូវបទប្បញ្ញត្តិ ដែលមានលក្ខណៈល្អប្រសើរ គ្របដណ្តប់លើសសរស្តម្ភទាំងបួននៃការវិនិយោគ រួមមានការការពារ ការធ្វើសេរីភាវូបនីយកម្ម ការលើកកម្ពស់ និងកិច្ចសម្រួលវិនិយោគ បន្ថែមពីលើអ្វីដែលមានស្រាប់នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន ព្រមទាំងអនុញ្ញាតឱ្យកែលម្អបទប្បញ្ញត្តិ កិច្ចសម្រួលវិនិយោគ ដែលនឹងជួយដោះស្រាយកង្វល់របស់អ្នកវិនិយោគ ដូចជាការដោះស្រាយបណ្តឹងតវ៉ា និងការតវ៉ាដែលអាចកើតមាន។

- **ជំពូកទី១១ កម្មសិទ្ធិបញ្ញា** បានដាក់ចេញនូវវិធីសាស្ត្រដែលមានតុល្យភាពនិងប្រកបដោយបរិយាប័ន្ន ក្នុងការការពារ និងពង្រឹងការអនុវត្តច្បាប់សិទ្ធិកម្មសិទ្ធិបញ្ញានៅក្នុងតំបន់ ព្រមទាំងលើកកម្ពស់កិច្ចការពារកម្មសិទ្ធិបញ្ញា បន្ថែមពីលើក្របខ័ណ្ឌដែលផ្តល់ឱ្យក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក រួមមាន វិធានការការពារ បច្ចេកវិទ្យានិងការអនុវត្តសិទ្ធិឌីជីថល និងការដាក់ពាក្យស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិក ដែលសមស្របនឹងការមកដល់នៃយុគសម័យឌីជីថល ។

- **ជំពូកទី១២ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** បានជំរុញការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងកិច្ចសហប្រតិបត្តិការក្នុងចំណោមបណ្តាភាគី។ ភាគីអាសិបក៏បានយល់ព្រមរក្សាការអនុវត្តបច្ចុប្បន្ននៃការមិនអនុវត្តពន្ធគយសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ស្របតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោក។

- **ជំពូកទី១៣ ការប្រកួតប្រជែង** បានលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច និងសុខុមាលភាពអ្នកប្រើប្រាស់ ដោយផ្តល់សិទ្ធិដល់ភាគីនីមួយៗក្នុងការបង្កើត ឬរក្សាច្បាប់ប្រកួតប្រជែងដែលមានស្រាប់ និងសមត្ថកិច្ចក្នុងការហាមឃាត់សកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង បទប្បញ្ញត្តិស្តីពីការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលក្នុងសកម្មភាពអនុវត្តច្បាប់។

- **ជំពូកទី១៤ សហគ្រាសធុនតូច និងមធ្យម** បានជំរុញឱ្យមានការអនុវត្តកម្មវិធីសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងសកម្មភាពសេដ្ឋកិច្ចនានា សំដៅបង្កើន សមត្ថភាពរបស់សហគ្រាសធុនតូច និងមធ្យម ក្នុងការប្រើប្រាស់ និងទាញប្រយោជន៍ពីកាលានុវត្តភាពពីកិច្ចព្រមព្រៀងអាសិប ជាពិសេសការធ្វើសមាហរណកម្ម ចូលក្នុងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ ជាដើម។

- **ជំពូកទី១៥ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស** បានផ្តោតជាចម្បងលើការបង្រួមគម្លាតអភិវឌ្ឍន៍ តាមរយៈកម្មវិធីជំនួយបច្ចេកទេសនិងកសាងសមត្ថភាពនានា ក្នុងការគាំទ្រដល់ការអនុវត្ត និងប្រើប្រាស់កិច្ចព្រមព្រៀងនេះយ៉ាងមានប្រសិទ្ធភាព ដោយផ្តល់អាទិភាពដល់ប្រទេសអភិវឌ្ឍន៍តិចតួច។

- **ជំពូកទី១៦ លទ្ធកម្មរដ្ឋាភិបាល** បានលើកកម្ពស់តម្លាភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានានិងបង្កើនកិច្ចសហប្រតិបត្តិការរវាងភាគីទាំងអស់ក្នុងកិច្ចការលទ្ធកម្មរដ្ឋាភិបាល។

- **ជំពូកទី១៧ បទប្បញ្ញត្តិទូទៅនិងការលើកលែង** បានកំណត់កាតព្វកិច្ចនានារបស់ភាគីទាំងអស់ ពាក់ព័ន្ធនឹងការបោះពុម្ពផ្សាយ ការផ្តល់ព័ត៌មាន នីតិវិធីរដ្ឋបាលអនុវត្តលើច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានាក៏ដូចជាការអនុវត្តសេចក្តីសម្រេចរដ្ឋបាល ការត្រួតពិនិត្យឡើងវិញ និងបណ្តឹងឧទ្ធរណ៍ ការលាតត្រដាងព័ត៌មាន និងព័ត៌មានសម្ងាត់ ដោយភាគីកិច្ចព្រមព្រៀងអាសិបទាំងអស់អាចរក្សាសិទ្ធិ គ្រប់គ្រងលើបញ្ហានានាពាក់ព័ន្ធនឹងប្រយោជន៍សាធារណៈ។

- **ជំពូកទី១៨ បទប្បញ្ញត្តិស្ថាប័ន** បានបង្កើតឱ្យមានការរៀបចំផ្នែកស្ថាប័នសម្រាប់កិច្ចព្រមព្រៀងអាសិប និងរចនាសម្ព័ន្ធសម្រាប់រដ្ឋមន្ត្រីអាសិប គណៈកម្មាធិការចម្រុះអាសិប និងគណៈកម្មាធិការ/អនុគណៈកម្មាធិការផ្សេងៗទៀត។ គណៈកម្មាធិការចម្រុះអាសិប នឹងពិនិត្យនិងចង្អុលបង្ហាញណែនាំការអនុវត្តកិច្ចព្រមព្រៀងអាសិបនេះ។

- **ជំពូកទី១៩ ការដោះស្រាយវិវាទ** បានបង្កើតឱ្យមាននូវយន្តការប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព សម្រាប់ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ ដែលកើតចេញពីការអនុវត្តកិច្ចព្រមព្រៀងអាសិបនេះ។

- **ជំពូកទី២០ អវសានប្បញ្ញត្តិ** បានកំណត់ពីការត្រួតពិនិត្យឡើងវិញទូទៅ និងនីតិវិធីធ្វើវិសោធនកម្មកិច្ចព្រមព្រៀង បញ្ញត្តិស្តីពីការចូលជាធរមាន ការដកខ្លួនចេញពីកិច្ចព្រមព្រៀង និងការចូលជាសមាជិកកិច្ចព្រមព្រៀងអាសិប។

អត្ថបទច្បាប់នៃកិច្ចព្រមព្រៀងអាសិប អាចទាញយកបាននៅលើគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម (www.moc.gov.kh)។ ចំពោះអ្នកនាំចេញទំនិញ ដែលមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់អាសិប (Form RCEP) សម្រាប់ការនាំចេញទំនិញទៅកាន់បណ្តាទីផ្សារអាសិប អាចដាក់ពាក្យស្នើសុំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ដែលមានគេហទំព័រ https://co.moc.gov.kh។

ថ្ងៃពុធ ៣រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១

**ចំពោះព័ត៌មានពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញនិងការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ សូមទំនាក់ទំនង៖**
-លោក អ៊ុន ចាន់ថា ប្រធាននាយកដ្ឋាននាំចេញ-នាំចូល
លេខទូរស័ព្ទ៖ ០៩៧ ៧៥២ ៥១៣៥
-លោក ស៊ី បាទិត្យ អនុប្រធាននាយកដ្ឋាននាំចេញ-នាំចូល
លេខទូរស័ព្ទ៖ ០១២ ៩៤ ៨៤ ៨៤
**ចំពោះព័ត៌មានពាក់ព័ន្ធនឹងអត្ថបទកិច្ចព្រមព្រៀង សូមទំនាក់ទំនង៖**
-លោក អេង សុធីវ័ន្ត ប្រធាននាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក
លេខទូរស័ព្ទ៖ ០៩៧ ២៦១ ៩៩៩៩
-លោក តែ រតនា អនុប្រធាននាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក
លេខទូរស័ព្ទ៖ ០៨៩ ៦៩៩ ៩៨៩